# គំរូរបស់ ព្រិកហាំ យ៉ង់

## ការពិភាក្សាទី១

**បញ្ហាប្រឈមមុខនៃការនិយាយជាសាធារណៈ**

សូមចាប់ផ្ដើមសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះការនិយាយជាសាធារណៈនេះ ? ហេតុអ្វី ?

សូមអាន ឬសង្ខេបដូចខាងក្រោមនេះ ៖

ឧបសគ្គដ៏ធំបំផុតមួយរបស់ព្រិកហាំ យ៉ង់ គឺការនិយាយជាសាធារណៈ ។ លោកបាននិយាយថា ៖ « ខ្ញុំមិនមែនជាមនុស្សពូកែនិយាយនោះទេ » ( នៅក្នុង *Journal of Discourses* ៥:៩៧ ) ។ លោកបានរំឭកពីគ្រាមួយ នៅមួយសប្ដាហ៍បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់លោក នៅពេលលោករំពឹងថា នឹងមានអ្នកនិយាយដែលមានបទពិសោធន៍បួននាក់ ដែលជាសមាជិកនៃសាសនាចក្រឡើងផ្សព្វផ្សាយ ប៉ុន្តែពួកគេមិនបានធ្វើនោះទេ ។ លោកបានថ្លែងថា ៖



ខ្ញុំនៅក្មេង កន្លងមកការនិយាយជាសាធារណៈ និងចំណេះដឹងពីពិភពលោកមិនពូកែនោះទេ ប៉ុន្តែ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើរូបខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថា ឆ្អឹងរបស់ខ្ញុំនឹងស៊ីសាច់នៅក្នុងខ្លួនខ្ញុំ លុះត្រាតែខ្ញុំនិយាយទៅកាន់គេ ហើយប្រាប់ពួកគេពីអ្វីដែលខ្ញុំបានឃើញ បានឮ និងបានរៀន—អ្វីដែលខ្ញុំបានឆ្លងកាត់ និងអ្វីដែលធ្វើឲ្យខ្ញុំរីករាយ ហើយ ខ្ញុំបាននិយាយជាងមួយម៉ោងក្នុងសុន្ទរកថាដំបូងរបស់ខ្ញុំ ។ ខ្ញុំបានបើកមាត់និយាយ ហើយព្រះអម្ចាស់បានបំពេញការនិយាយរបស់ខ្ញុំ ។ ( ព្រិកហាំ យ៉ង់ នៅក្នុង *Journal of Discourses* ១៣:២១១ )

- តើអ្វីដែលព្រិកហាំ យ៉ង់ បានធ្វើមានការពិបាកអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ១០០:៥–៦ ( សូមមើលផងដែរ និក្ខមនំ ៤:១២; សុភាសិត ១៦:១ ) ។ បន្ទាប់មកសូមសួរ ៖

- តើបទពិសោធន៍របស់ព្រិកហាំ យ៉ង់ ទាក់ទងនឹងខគម្ពីរទាំងនេះយ៉ាងដូចម្ដេច ?
- តើអ្នករៀនអ្វីខ្លះអំពីព្រះអម្ចាស់ដែលអាចជួយអ្នកបាន ?

សូមចែកចាយអំពីអារម្មណ៍របស់អ្នកអំពីការទុកចិត្តលើព្រះអម្ចាស់ ហើយមានឆន្ទៈចែកចាយនូវអ្វីដែលអ្នកដឹង ។

## ការពិភាក្សាទី ២

**ការលះបង់របស់ព្រិកហាំ ដើម្បីបម្រើ**

ចាប់ផ្ដើមដោយការសួរសំណួរដូចខាងក្រោម ៖

- តើការបម្រើបេសកកម្មត្រូវលះបង់អ្វីខ្លះ ?

សូមអាន ឬសង្ខេបដូចខាងក្រោមនេះ ៖

នៅក្នុងឆ្នាំដដែលនោះ នៅពេលព្រិកហាំ យ៉ង់ បានទទួលបុណ្យជ្រមុជទឹក ភរិយារបស់លោកបានទទួលមរណភាព ។ ជាការលះបង់ដ៏ធំ លោកបានរៀបចំឲ្យមានការមើលថែកូនទាំងពីរនាក់របស់លោក ហើយបានបម្រើបេសកកម្មទៅទីក្រុងញូវយ៉ក និងកាណាដាខាងលើ ជាកន្លែងដែលលោកបានជ្រមុជទឹកមនុស្សជាច្រើន ។

បន្ទាប់ពីបានបម្រើបេសកកម្មអស់រយៈពេលជិតមួយឆ្នាំ ព្រិកហាំ បានពិពណ៌នាអំពីការមកដល់របស់លោកក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូ ៖



បើមានមនុស្សណាម្នាក់ដែលធ្លាប់ជួបជុំជាមួយពួកបរិសុទ្ធគឺជាអ្នកក្រជាងខ្ញុំ—នោះវាគឺដោយសារតែគាត់គ្មានអ្វីទាល់តែសោះ ។ . . . ខ្ញុំមានកូនពីរនាក់ដើម្បីមើលថែ ។ . . . ខ្ញុំជាបុរសពោះម៉ាយ ។ . . . [ ខ្ញុំ ] គ្មានស្បែកជើងពាក់ទេ មានតែស្បែកជើងកវែងដែលខ្ចីគេមួយគូនេះ ។ ខ្ញុំគ្មានអាវងារទេ មានតែអាវដែលដេរដោយដៃដែលខ្ញុំមានតាំងពីពេលបី ឬបួនឆ្នាំមុនម្ល៉េះ ។ . . . ខ្ញុំបានធ្វើដំណើរ ហើយផ្សព្វផ្សាយ ហើយបានបរិច្ចាគប្រាក់កាសនៃទ្រព្យសម្បត្តិរបស់ខ្ញុំដែលមាន ។ ( *Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ ១៩៩៧ ] ទំព័រ ២៤៣ )